រឿង

# សូមមេត្តាបើកទ្វារឱ្យខ្ញុំផង



# រឿង សូមមេត្តាបើកទ្វារឱ្យខ្ញុំផង

និពន្ធដោយ លោក វ៉ា សំអាត
គូររូបដោយ លោក ចាន់ សោភ័ណ
រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)
បោះពុម្ពឆ្នាំ២០០៩

# រឿង សូមមេត្តាបើកទ្វារឱ្យខ្ញុំផង




និពន្ធដោយ វ៉ា សំអាត

វិចិត្ររូបភាពដោយ ចាន់ សោភ័ណ



បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត



ទឹកជំនន់ដ៏ធំបានធ្វើឱ្យភូមិមួយ នៅតាមមាត់ទន្លេមេគង្គលិចលង់ទាំងស្រុង ។ អ្នកភូមិទាំងអស់បានជម្លៀសទៅរស់នៅតំបន់សុវត្ថិភាព ។



ពេលនោះ មានឆ្កែមួយ និងឆ្មាពីរនាក់ប្ដីប្រពន្ធបានវង្វេងម្ចាស់ ហើយ ឡើងទៅស្នាក់នៅលើកាណូតដឹកទំនិញដ៏ធំមួយ ដែលគេទុកសម្រាប់ជួសជុល ។





ឆ្កែស្នាក់នៅក្នុងបន្ទប់ផ្ទុកទំនិញ ។



ចំណែកឯឆ្មាទាំងពីរស្ទាក់នៅក្នុងបន្ទប់ចំអិនអាហារ ។







ឆ្មាទាំងពីរខ្លាចឆ្កែណាស់ ។ គេទាំងពីរបិទទ្វារបន្ទប់ ហើយដាក់គន្លឹះយ៉ាងជាប់ទៀតផង ។ មួយថ្ងៃបានរំលងផុតទៅ... ព្រឹកមួយឆ្កែបានគោះទ្វារបន្ទប់របស់ឆ្មា ព្រមទាំងស្រែកហៅដោយសំដីគួរសមថា "សូមមេត្តាបើកទ្វារឱ្យខ្ញុំផង! ខ្ញុំត្រូវការកាំបិតហាន់សាច់ និងចានដាក់សាច់មួយ" ។



នៅក្នុងបន្ទប់ ឆ្មាទាំងពីរសម្លឹងមុខគ្នាដោយភ័យខ្លាច ។ ឆ្មាជាប្ដីនិយាយថា "គេត្រូវការកាំបិត និងចាន! សំដីគេប្រកបដោយមិត្តភាព បងគិតថាតើយើងគួរបើកទ្វារឱ្យគេឬយ៉ាងណា" ឆ្មាជាប្រពន្ធមិនបានតបអ្វីសោះ ។ ស្នូរគោះទ្វារជាលើកទីពីរ តុក! តុក! តុក! "សូមមេត្តាបើកទ្វារឱ្យខ្ញុំផង! ខ្ញុំត្រូវការជ្រុញមួយ"។ ឆ្មាជាប្រពន្ធខ្សឹបថា"គេរកជ្រុញប្រហែលទុកសម្រាប់ហាន់សាច់យើងហើយ ។ យើងកុំចាញ់បោកគេ ដាច់ខាតយើងមិនត្រូវបើកទ្វារឱ្យទេ! " ។





នៅពេលថ្ងៃត្រង់ ស្គួរគោះទ្វារជាលើកទីបី តុក! តុក! តុក! "សូមមេត្តា
បើកទ្វារឱ្យខ្ញុំផង! ខ្ញុំសូមខ្ចីឆ្នាំងមួយមក" ឆ្កែនិយាយដោយសុភាពរាបសា ។

ឆ្មាទាំងពីរកាន់តែភ័យតក់ស្លុតខ្លាំងឡើងៗ ហើយរត់ទៅពួននៅកៀនជញ្ជាំង ភ្នែកសម្លឹងទៅមាត់ទ្វារ ។ ឆ្មាជាប្រពន្ធនិយាយដោយសំឡេងញ័រៗ "គេរកផ្ទាំងសម្រាប់ស្លសាច់យើងប្រាកដណាស់" ។ បន្ទាប់មកស្គរគោះទ្វារជាលើកទីបួន តុក! តុក! តុក! "សូមមេត្តាបើកទ្វារឱ្យខ្ញុំផង! ឱ្យខ្ញុំសុំគ្រឿងប្រឡាក់សាច់ខ្លះមក" ឆ្កែនិយាយដោយសំដីស្លូតបូត ។





ឆ្មាជាប្ដីខ្សឹបថា "នៅទីនេះយើងគ្មានអ្វីហូបទេ ។ យើងរស់នៅបាន យ៉ាងយូរត្រឹមតែពីរ បីថ្ងៃទៀតប៉ុណ្ណោះ ។ បើតាមស្ដាប់ពាក្យសម្ដីទន់ភ្លន់ សុភាពរាបសារបស់គេ យើងគួរតែបើកទ្វារឱ្យគេទៅ! ប្រសិនបើគេប៉ុនប៉ង ជីវិតយើងពិតមែន យើងត្រូវតែតតាំងតបវិញ" ។





ថ្ងៃរៀបលិច ស្ទួរគោះទ្វារជាលើកទីប្រាំ តុក!  តុក! តុក! "សូមមេត្តា
បើកទ្វារឱ្យខ្ញុំផង! ឱ្យខ្ញុំសុំខ្ទឹចង្ក្រានហ្គាសផង" ឆ្កែនិយាយអង្វរ ។



ឆ្មាជាប្រពន្ធបានពោលតិចៗថា "ពាក្យអង្គរករនេះសុទ្ធតែជាឧបាយកល យកល្អយើងគួរតែរកផ្លូវរត់ចេញពីទីនេះទៅ" ។ ឆ្មាជាប្តីតប "យើងអាច ទម្លាយជញ្ជាំងបន្ទប់ចេញទៅក្រៅបាន ប៉ុន្តែបើផ្ទៃទឹកធំល្វឹងល្វើយយ៉ាងនេះ តើធ្វើដូចម្តេចទើបយើងអាចទៅដល់ទីគោកបាន?" ។





ឆ្មាបានឮសូរហាក់ដូចជាឆ្កែកំពុងតិបតុបៗ ធ្វើអ្វីមួយមិនឈប់ឈរ និង មានធុំក្លិនឈ្ងុយជះចូលមកក្នុងបន្ទប់ទៀតផង ។



មួយសន្ទុះក្រោយមក ឆ្មាបានឮឆ្កែនិយាយនៅមុខបន្ទប់ថា "មិត្តទាំងពីរប្រហែលជាឃ្លានខ្លាំងហើយ! ខ្ញុំបានធ្វើអាហារដែលមានរសជាតិឆ្ងាញ់សម្រាប់អ្នកទាំងពីរ... សូមមេត្តាបើកទ្វារឱ្យខ្ញុំផង!" ។





ទ្វារបន្ទប់បើកឡើង ឆ្កែឈរមាត់ទ្វារ ញញឹមដាក់ឆ្មាទាំងពីរ ដោយមានកាន់ចានអាហារក្ដៅហុយៗ ដែលមានក្លិនយ៉ាងឈ្ងុយឆ្ងាញ់នៅដៃស្ដាំ និងកាន់ភ្លើងចន្លុះមួយដើមនៅដៃឆ្វេង ។





ឆ្មាទាំងពីរពិសាអាហារជាមួយឆ្កែយ៉ាងរីករាយ នៅក្នុងបន្ទប់ផ្ទុកទំនិញដ៏ធំទូលាយដែលមានខ្យល់អាកាសល្អ ។





លុះព្រឹកឡើង ក្រុមសង្គ្រោះ ព្រមទាំងម្ចាស់របស់ឆ្កែ និងឆ្មាទាំងពីរ បានមករកពួកគេឃើញ ហើយក៏នាំពួកគេទៅកាន់ទីសុវត្ថិភាព ។

...ចប់...





អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association